88

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យជាតិគ្រប់គ្រង

សាលាក្រោយឧត្តម

# យុទ្ធសាស្ត្រទាក់ទាញវិនិយោគិនវិស័យឧស្សាហ៍កម្មកាត់ដេរមកកម្ពុជា

ខេង ច័ន្ទដាលុច្យ

កិច្ចការស្រាវជ្រាវ បំពេញលក្ខខណ្ឌក្នុងការប្រឡងបញ្ចប់
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងពាណិជ្ជកម្ម

ជំនាញ

គ្រប់គ្រងពាណិជ្ជកម្ម

.6
E

សាកលវិទ្យាល័យជាតិគ្រប់គ្រង

រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

ឆ្នាំសិក្សា ២០១៩

**ក្រសួងអប់រំ យុវជន និងកីឡា**

**សាកលវិទ្យាល័យជាតិគ្រប់គ្រង**

សាលាក្រោយឧត្តម

# យុទ្ធសាស្ត្រទាក់ទាញវិនិយោគិនវិស័យឧស្សាហ៍កម្មកាត់ដេរ មកកម្ពុជា

សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management
បណ្ណាល័យ LIBRARY
លេខបញ្ជី INVENTORY №..........
ថ្ងៃចូល ENTRY DATE 01 . 11 . 2019

**ខេង ច័ន្ទដាលុច្យ**

កិច្ចការស្រាវជ្រាវ បំពេញលក្ខខណ្ឌក្នុងការប្រឡងបញ្ចប់ថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងពាណិជ្ជកម្ម

**ជំនាញ**

**គ្រប់គ្រងពាណិជ្ជកម្ម**

សាកលវិទ្យាល័យជាតិគ្រប់គ្រង

**ភ្នំពេញ កម្ពុជា**

**ឆ្នាំសិក្សា ២០១៩**

# ក្រសួងអប់រំ យុវជន និងកីឡា

## សាកលវិទ្យាល័យជាតិគ្រប់គ្រង

សាលាក្រោយឧត្តម

# យុទ្ធសាស្ត្រទាក់ទាញវិនិយោគិនវិស័យឧស្សាហកម្មកាត់ដេរ មកកម្ពុជា

**ខេង ច័ន្ទដាលុច្យ**

កិច្ចការស្រាវជ្រាវ បំពេញលក្ខខណ្ឌក្នុងការប្រឡងបញ្ចប់ថ្នាក់
បរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងពាណិជ្ជកម្ម

ណែនាំដោយ :

_______________________________

សាស្ត្រាចារ្យ កង សុវណ្ណារ៉ា

សាកលវិទ្យាល័យជាតិគ្រប់គ្រង

ភ្នំពេញ កម្ពុជា

ឆ្នាំសិក្សា ២០១៩

មាតិកា


I. សេចក្តីផ្តើម

១.១ទិដ្ឋភាពទូទៅ......1

១.២ សារតានៃបញ្ហា......2

១.៣ ចំណោទបញ្ហា......3

១.៤ គោលបំណងនៃការសិក្សា......6

១.៥. សារៈប្រយោជន៍នៃការសិក្សា ( Significance of Study)......7

១.៦. វិធីសាស្ត្រស្រាវជ្រាវ......7

II. យុទ្ធសាស្ត្រទាក់ទាញវិនិយោគិនវិស័យឧស្សាហ៍កម្មកាត់

២.១ រំលឹកទ្រឹស្តី......8

២.១.១ ដូចម្តេចហៅថាការវិនិយោគ? ......8

២.១.២ ដូចម្តេចហៅថាយុទ្ធសាស្ត្រទាក់ទាញ? ......9

២.១.៣ ច្បាប់និងគោលនយោបាយទាក់ទាញអ្នកវិនិយោគនៅកម្ពុជា...12

២.១.៤ ការវិនិយោគលើវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជា......14



សាកលវិទ្យាល័យជាតិគ្រប់គ្រង

២.២ កត្តាជាយុទ្ធសាស្ត្រទាក់ទាញអ្នកវិនិយោគក្នុងវិស័យកាត់ដេរនៅកម្ពុជា........................................16

២.២.១ សន្តិសុខសុវត្ថិភាព........................................16

២.២.២ ធនធានមនុស្ស........................................18

២.២.៣ គោលនយោបាលពន្ធ........................................19

២.២.៤ អភិបាលកិច្ចល្អ........................................19

២.២.៥ ហេដ្ឋារចនាសម្ព័ន្ធ........................................20

III. សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៣.១ សន្និដ្ឋាន........................................21

៣.២ អនុសាសន៍........................................22

ឯកសារយោង........................................24

សាកលវិទ្យាល័យជាតិគ្រប់គ្រង

# I. សេចក្ដីផ្ដើម

## ១.១ទិដ្ឋភាពទូទៅ

សេដ្ឋកិច្ចប្រទេសមួយរីកចម្រើនទៅបានគឺអាស្រ័យប្រទេសនោះមានទំនាក់ទំនងពាណិជ្ជកម្មជាមួយបណ្ដាប្រទេសដទៃ ដោយធ្វើការដោះដូរទំនិញសេវាកម្មឬមូលធនផ្សេងៗ។ ប្រទេសខ្លះពឹងផ្អែកលើការលំហូរចូលនៃអ្នកវិនិយោគិនបរទេសដែលមករកស៊ីក្នុង ប្រទេសរបស់ខ្លួនហើយផលចំនេញដែលទទួលបានមកពិការវិនិយោគនេះបានរួមចំនែកក្នុងការជំរុញសេដ្ឋកិច្ចអោយមានការរីកចម្រើន។ជាតួយ៉ាងប្រទេសកម្ពុជាបានពឹងផ្អែកលើវិស័យកាត់ដេរដែលជាវិស័យចំបងមួយក្នុងការធ្វើអោយសេដ្ឋកិច្ចមានការរីកចម្រើន។

ទន្ទឹមនិងនោះគេឃើញថាវិស័យកាត់ដេរនៅកម្ពុជាត្រូវប្រឈមមុខនឹងបញ្ហាធំៗមួយចំនួនទាំងនៅក្នុងពេលបច្ចុប្បន្ននិងសម្រាប់ថ្ងៃអនាគតដូចជា ការកើនឡើងនៃប្រាក់ឈ្នួលកម្មករ ការកើនឡើងនៃថ្លៃផលិត ការអស់សុពលភាពនៃកិច្ចព្រមព្រៀងសរសៃអំបោះ (MFA) និងការធ្វើកូដកម្មដោយមិនគោរពតាមនីតិវិធីច្បាប់ការងារៗកិច្ចការស្រាវជ្រាវនេះនឹងបង្ហាញអំពីការសិក្សាកត្តាយុទ្ធសាស្ត្រក្នុងការទាក់ទាញវិនិយោគិនវិស័យឧស្សាហ៍កម្មកាត់ដេរមកកម្ពុជារបស់រាជរដ្ឋាភិបាលដែលរួមមាន សុខសុវត្ថិភាព ធនធានមនុស្ស គោលនិយោបាយពន្ធ អភិបាលកិច្ចល្អ និងហេដ្ឋារចនាសម្ព័ន្ធ។

កិច្ចការស្រាវជ្រាវនេះយើងនិងបង្កើតកម្រងសំនួរដើម្បីសាកសួរអ្នកតំណាងរោងចក្រចំនួន១៩៩រោងចក្រអំពីមតិយោបល់របស់គេ។ ហើយលទ្ធផលអាចមានសារៈសំខាន់សម្រាប់រាជរដ្ឋាភិបាលដើម្បីសិក្សាបន្ថែមលើគោលនយោបាយដែលមានស្រាប់និងមិនទាន់មានក្ដីដែលជាយន្តការក្នុងការទាក់ទាញវិនិយោគិនកមកកម្ពុជា។

ពាក្យគន្លឹះ ៖ ការសិក្សាយុទ្ធសាស្ត្រទាក់ទាញ សុខសុវត្ថិភាព ធនធានមនុស្ស គោលនយោបាយពន្ធ អភិបាលកិច្ចល្អ និងហេដ្ឋារចនាសម្ព័ន្ធ។

វិទ្យាស្ថានជាតិគ្រប់គ្រង សាកលវិទ្យាល័យជាតិគ្រប់គ្រង

## ១.២ សារតានៃបញ្ហា

កម្ពុជាត្រូវបានគេចាត់បញ្ចូលទៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ហើយជាទូទៅគេសង្កេតឃើញថាវិស័យកាត់ដេរស្ថិតក្នុងចំណោមវិស័យសំខាន់ៗដែលជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ចនេះ។ អស់រយៈពេលជាង១ទសវត្សរ៍មកហើយ ដែលកម្ពុជាមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងចន្លោះពី ៧ % ទៅ ១៣ %។ វិស័យកាត់ដេរគឺជាកម្លាំងចលករដ៏ធំមួយនៃកំណើនសេដ្ឋកិច្ចនេះ។នៅក្នុងចំណោមការនាំចេញទំនិញរបស់

កម្ពុជាទៅក្រៅប្រទេសក្នុងមួយឆ្នាំៗមានប្រមាណជា៨០%។ទឹកប្រាក់ដែលទទួលបានមកពីវិស័យកាត់ដេរគឺមានរហូតដល់ជាង៥ពាន់លានដុល្លារកាលពីឆ្នាំ ២០១៣ កន្លងមក។ បើយោងតាមវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា គិតចាប់តាំងពីឆ្នាំ ១៩៩៥ មក

គ្រាន់តែវិស័យកាត់ដេរមួយបានជួយជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាប្រមាណជា

២ % ក្នុងមួយឆ្នាំ។

ក្នុងពេលជាមួយគ្នានេះ វិស័យកាត់ដេរក៏ចូលរួមចំណែកដ៏សំខាន់ផងដែរនៅក្នុងការពង្រីកទីផ្សារការងារនៅកម្ពុជា។ ហើយបើយោងតាមក្រសួងការងារកម្ពុជាមានរោងចក្រកាត់ដេរសរុប នៅទូទាំងប្រទេសប្រមាណជា៥៥៩រោងចក្រ ហើយក៏បានបង្កើតការងារដល់ប្រជាជនរហូតដល់ទៅប្រមាណជា៦សែននាក់។ ជាការពិតណាស់គេអាចនិយាយ បានថាវិស័យកាត់ដេរគឺជាប្រភពចំណូលដ៏សំខាន់មួយសម្រាប់ថវិកាជាតិគឺចំណូលតាមរយៈការប្រមូលពន្ធ។ ក៏ប៉ុន្តែចំណូលសម្រាប់ថវិកាជាតិនេះក៏ត្រូវកាត់បន្ថយខ្លះផងដែរ ដោយសារតែការវិនិយោគលើវិស័យកាត់ដេរសម្រាប់នាំចេញ ស្ថិតក្នុងចំណោមវិស័យវិនិយោគដែលទទួលបាននូវការអនុគ្រោះពន្ធ។ នៅក្នុងរយៈពេលអនុគ្រោះពន្ធនេះ (ដែលក្នុងករណីខ្លះអាចមានរយៈពេលរហូតដល់ទៅ៩ឆ្នាំ) រោងចក្រកាត់ដេរត្រូវបានរួចពន្ធ ទាំងទៅលើប្រាក់ចំណេញ និងទាំងពន្ធគយទៅលើការនាំចូល

សម្ភារៈ ដែលចាំបាច់ក្នុងការផលិត ដូចជា វត្ថុធាតុដើមនិងគ្រឿងម៉ាស៊ីនផ្សេងៗ

ជាដើម។

កិច្ចការស្រាវជ្រាវនេះគឺសិក្សាស្រាវជ្រាវផ្តោតទៅលើការសិក្សា

យុទ្ធសាស្ត្រក្នុងការទាក់ទាញវិនិយោគិនវិស័យកាត់ដេរមកកម្ពុជា។ ថាតើកម្ពុជាធ្វើអោយប្រសើរលើកត្តាអ្វីដែលជាសក្តានុពលសម្រាប់ទាញចំនាប់អារម្មណ៍របស់

វិនិយោគិនបរទេសមកវិនិយោគក្នុងស្រុក។ លើសពីនេះទៅទៀតតើកម្ពុជាមានកត្តាអ្វីដែលធ្វើអោយអ្នកវិនិយោគងាករេចិត្តមិនមកវិនិយោគ ឬក៏ដកការ

វិនិយោគពីកម្ពុជាទៅវិនិយោគឯប្រទេសជិតខាង។

១.៣ ចំណោទបញ្ហា

គេឃើញថាវិស័យកាត់ដេរនៅកម្ពុជាត្រូវប្រឈមមុខនឹងបញ្ហាធំៗមួយចំនួនទាំងនៅក្នុងពេលបច្ចុប្បន្ននិងសម្រាប់ថ្ងៃអនាគត។ បញ្ហាចម្បងទីមួយ គឺការកើនឡើងនៃប្រាក់ឈ្នួលកម្មករ។ នៅពេលដែលសេដ្ឋកិច្ចមានការអភិវឌ្ឍហើយបូករួមជាមួយនឹងអតិផរណាផង តម្រូវការនៃជីវភាពរបស់ប្រជាជនក៏មានការកើនឡើង ដែលជាហេតុធ្វើឲ្យកម្មករនិយោជិតទាមទារប្រាក់ខែកាន់តែខ្ពស់។ ចលនាបាតុកម្ម និងកូដកម្មរបស់កម្មករកាត់ដេរ ដើម្បីទាមទារដំឡើងប្រាក់ឈ្នួល នាពេលថ្មីៗកន្លងទៅ គឺជាការបង្ហាញឲ្យឃើញកាន់តែច្បាស់អំពីបញ្ហានេះ។

បន្ថែមពីលើការកើនឡើងនៃតម្លៃកម្លាំងពលកម្មនេះថ្លៃបន្ទាប់ បន្សំផ្សេងៗទៀតដែលទាក់ទងនឹងការផលិតនិងការនាំចេញក្នុងវិស័យកាត់ដេរក៏មានកម្រិតខ្ពស់ផងដែរ បើប្រៀបធៀបនឹងប្រទេសជិតខាង ដូចជា ថ្លៃអគ្គិសនី និងថ្លៃដឹកជញ្ជូន ជាដើម។ នេះនៅមិនទាន់គិតអំពីការចំណាយក្រៅផ្លូវការផ្សេងទៀតដែលកើតឡើងពីអំពើពុករលួយ។ ទាំងអស់នេះធ្វើឲ្យថ្លៃផលិតត្រូវកើនឡើងហើយអាចនឹងធ្វើឲ្យវិស័យកាត់ដេរកម្ពុជាត្រូវបាត់បង់ភាពប្រកួតប្រជែងធៀបនឹង

ប្រទេសផ្សេងទៀត។ លើសពីនេះទៅទៀតវិស័យកាត់ដេរនៅកម្ពុជា ក៏ជួបប្រទះនូវផលវិបាកមួយចំនួនទាក់ទងនឹងថ្លៃដើមផលិតកម្មផងដែរ ជាពិសេសគឺថ្លៃ

អគ្គិសនីតែម្តង។ យ៉ាងណាមិញផលិតករនៅកម្ពុជាបង់ ០.១៥ US/KWhr លើថ្លៃអគ្គិសនី។ នេះជាថ្លៃយ៉ាងខ្ពស់បំផុត បើធៀបជាមួយដៃគូប្រកួតប្រជែងផ្សេងៗទៀត។ យ៉ាងណាមិញនៅប្រទេសបង់ក្លាដេស ថ្លៃអគ្គិសនីស្មើនឹង ០.០៦៥ US/KWhr នៅប្រទេសចិនគឺ ០.០៩៧-០.០៨US/KWhr និងនៅឥណ្ឌាគឺ ០.១០៥២US/KWhrដែលជាប្រទេសមានអត្រាខ្ពស់ទីពីរបន្ទាប់ពីប្រទេសកម្ពុជា។ តម្លៃអគ្គិសនីអន្តរជាតិគឺ ០.០៦US$/KWhr។ ដូច្នេះតម្លៃអគ្គិសនីរបស់កម្ពុជា គឺខ្ពស់ជាងអគ្គិសនីអន្តរជាតិ ១៥០%។

ក្រៅពីការកើនឡើងនៃថ្លៃផលិត នៅមានបញ្ហាប្រឈមដ៏ធំមួយទៀតសម្រាប់វិស័យកាត់ដេរកម្ពុជា គឺហានិភ័យនៃទីផ្សារអន្តរជាតិ។ ដូចដែលគ្រប់គ្នាដឹងស្រាប់ហើយថា ផលិតផលក្នុងវិស័យកាត់ដេរកម្ពុជា មិនមែនសម្រាប់លក់នៅលើទីផ្សារក្នុងស្រុកនោះទេ ប៉ុន្តែសម្រាប់នាំចេញទៅក្រៅប្រទេស ជាពិសេសទៅអឺរ៉ុប និងសហរដ្ឋអាមេរិក។ ដូច្នេះនៅពេលដែលបណ្តាប្រទេសអស់ទាំងនេះត្រូវជួបនឹងវិបត្តិសេដ្ឋកិច្ច តម្រូវការនៃទីផ្សារនៅក្នុងប្រទេសទាំងនេះក៏ត្រូវធ្លាក់ចុះហើយការនាំចេញនៃវិស័យកាត់ដេររបស់កម្ពុជាក៏ត្រូវធ្លាក់ចុះទៅតាមនោះ

ដែរ។

វិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៨ និងវិបត្តិបំណុលនៅអឺរ៉ុបនាពេលថ្មីៗនេះ គឺជាឧទាហរណ៍ជាក់ស្តែងមួយ ដែលបង្ហាញឲ្យឃើញ អំពីហានិភ័យនៃការពឹងផ្អែកខ្លាំងតែលើវិស័យកាត់ដេរមួយ នៅក្នុងការនាំចេញ។

លើសពីនេះទៀតវិស័យកាត់ដេរប្រឈមមុខជាមួយការធ្វើកូដកម្មដោយមិនគោរពតាមនីតិវិធីច្បាប់ការងារៈ បច្ចុប្បន្ននេះមានការកើតឡើងនូវការធ្វើកូដកម្មពីកម្មកររោងចក្រកាត់ដេរសំលៀកបំពាក់ស្ទើរតែជារៀងរាល់ថ្ងៃពិសេសនៅក្នុងក្រុងភ្នំពេញ ដែលកូដកម្មទាំងនេះគឺភាគច្រើនជាកូដកម្មខុសច្បាប់ ហើយកូដកម្មខ្លះឈានដល់ការបិទទ្វាររោងចក្រ ការគំរាមគំហែងដោយប្រើប្រាស់ទាំង

ពាក្រសំដី ការប្រើហឹង្សាដល់រាងកាយកម្មករផ្សេងទៀត ក្នុងចេតនាហាមឃាត់មិនឲ្យកម្មករផ្សេងចូលទៅធ្វើការ និងខ្លះបានឈានទៅជាបាតុកម្មខុសច្បាប់ ហើយក៏មានខ្លះក្លាយជាកុបកម្មតែម្តងដែលវាគឺជាការរំលោភបំពានដោយផ្ទាល់ទៅលើច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

ភាគច្រើននៃការការតវ៉ារបស់កម្មករ-កម្មការិនី ត្រូវបានធ្វើឡើងតាមរយៈតំណាងរបស់ខ្លួនគឺសហជីពមូលដ្ឋានក្នុងរោងចក្រនោះផ្ទាល់តែម្តង។ ជាការកត់សម្គាល់នៅតាមបណ្តារោងចក្រភាគច្រើន បានផ្តល់អត្ថប្រយោជន៍ ដល់កម្មករនិយោជិតត្រឹមត្រូវទៅតាមច្បាប់ហើយ ខ្លះគឺច្រើនជាងច្បាប់ទៅទៀត ហើយការទាមទាររបស់តំណាងរោងកម្មករមួយចំនួនតូចទៅលើលក្ខខ័ណ្ឌការងារនោះគឺភាគច្រើនភាគីរោងចក្របានកំពុងត្រូវបានអនុវត្តនិងខ្លះអនុវត្តរួចហើយដែរ ប៉ុន្តែកូដកម្មនៅតែបន្តមានតាមរយៈការញុះញង់របស់ភាគីសហជីពខ្លះទៅវិញ។ ការប្រើហឹង្សាពីសំណាក់គុដករ បានបំផ្លាញនិងធ្វើឲ្យរាំងស្ទះសង្វាក់ផលិតកម្មដែលឈានដល់ការខាតបង់ថវិការាប់លានដុល្លាការបាត់បង់ការងាររបស់កម្មករ និងជាពិសេសអាចធ្វើឲ្យអ្នកវិនិយោគដកភាគហ៊ុនទៅវិនិយោគនៅប្រទេសដ៏ទៃដែលមានលក្ខខ័ណ្ឌល្អ។

ទន្ទឹមនិងនេះដែរវិស័យកាត់ប្រឈមមុខនឹងការអស់សុពលភាពនៃកិច្ចព្រមព្រៀងសរសៃអំបោះ (MFA) និង កិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និង

សំលៀកបំពាក់ (ATC) របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)៖ រហូតដល់ចុងឆ្នាំ ២០០៤ វិស័យកាត់ដេរនៅកម្ពុជាអាចប្រកួតជាមួយដៃគូប្រកួតប្រជែងសំខាន់ៗបានព្រោះដៃគូប្រកួតប្រជែងទាំងនេះត្រូវបង់ពន្ធខ្ពស់ បើពួកគេចង់លក់ឲ្យលើសពីកូតារបស់ពួកគេទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប។ ឥឡូវនេះកូតាត្រូវបានបញ្ចប់ទៅហើយ ក្រុមហ៊ុនកាត់ដេរកម្ពុជានឹងមានភាពលំបាកក្នុងការប្រកួតប្រជែងជាមួយក្រុមហ៊ុនផ្សេងទៀតនៅប្រទេសដ៏ទៃ ព្រោះថ្លៃដើមផលិតកម្មថ្លៃកប់ពពក។ នេះនឹងបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរដល់កំរិតការងារនិងសេដ្ឋកិច្ចជាតិ។

ហើយម្យ៉ាងវិញទៀតផលិតភាពការងាររបស់កម្មករនៅក្នុងវិស័យកាត់ដេរគឺមានកំរិតទាបនៅឡើយ។ បន្ទាប់ពីប្រាក់ឈ្នួលគោលរបស់កម្មករក្នុងវិស័យកាត់ដេរ និងដេរស្បែកជើងត្រូវបានកំណត់ត្រឹម១៨០ដុល្លា សម្រាប់ឆ្នាំ២០១៦ ហើយមកនៅថ្ងៃទី ២០ តុលានេះ សមាគមរោងចក្រកាត់ដេរនៅកម្ពុជាហៅកាត់ថា GMAC បានចេញសេចក្តីអំពាវនាវឲ្យមានការផ្តោតជាថ្មីលើការលើកកំពស់ផលិត ភាពការងារ និងគាំទ្រចំពោះការអំពាវនាវឲ្យអ្នកបញ្ជាទិញប្រើប្រាស់វិធីសាស្ត្រ បញ្ជាទិញដែលមាននិរន្តរភាពជាងមុន។ យោងតាមអង្គការអន្តរជាតិខាងការងារ ILO ផលិតភាពការងារក្នុងវិស័យកាត់ដេរកម្ពុជា ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ

បាននឹងកំពុងធ្លាក់ចុះ។

ដោយឃើញថាចំពោះវិស័យកាត់ដេរកម្ពុជាមានកត្តារារាំងជាច្រើនដែលធ្វើអោយវិស័យមួយនេះដើរទៅមុខមិនបានរលូនដូច្នេះហើយទើបកម្ពុជាមានភារកិច្ចចាំបាច់ធ្វើអោយប្រសើរឡើងចំពោះកត្តាដែលកើតមានឡើងចំពោះមុខដើម្បីទាក់ទាញវិនិយោគិនវិស័យកាត់ដេរអោយបានថេរឬក៍មានការកើនឡើងជាងមុន។

តើរាជរដ្ឋាភិបាលមានយុទ្ធសាស្ត្របែបណាក្នុងការទាក់ទាញវិនិយោគិនឧស្សាហ៍កម្មកាត់ដេរមកកម្ពុជា?

១.៤ គោលបំណងនៃការសិក្សា

គោលបំណងដ៏សំខាន់នៃការសិក្សាស្រាវជ្រាវពន្យល់អំពីគោលដៅរបស់អ្នកស្រាវជ្រាវនិងបង្ហាញអោយឃើញនូវចំនុចសំខាន់ៗនៃកិច្ចការស្រាវជ្រាវ។ គោលបំណងដ៏សំខាន់នៃការ។សិក្សាស្រាវជ្រាវនេះ គឺចង់ស្វែងយល់អំពីវាយតម្លៃប្រសិទ្ធិភាពនៃការកត្តាទាក់ទាញវិនិយោគិនឧស្សាហ៍កម្មកាត់ដេរមកកម្ពុជា។

សិក្សាគោយនយោបាយការទាក់ទាញវិនិយោគិនឧស្សាហ៍កម្មកាត់ដេរមកកម្ពុជាដែលមានស្រាប់របស់រាជរដ្ឋាភិបាលនិង គ).ផ្តល់សេចក្តីសន្និដ្ឋាន

និងអនុសាសន៍។

## ១.៥. សារៈប្រយោជន៍នៃការសិក្សា ( Significance of Study)

ប្រសិនបើការសិក្សាស្រាវជ្រាវនេះបានជោគជ័យវានឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់រដ្ឋាភិបាលក្នុងការធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយដែលមានស្រាប់ និងគោលនយោបាយមិនទាន់មានក្តីដើម្បីជាយុទ្ធសាស្រ្តក្នុងការទាក់ទាញវិនិយោគិនវិស័យឧស្សាហកម្មកាត់ដេរមកកម្ពុជា។ ហើយការសិក្សាស្រាវជ្រាវនេះក៏មានសារៈសំខាន់ផ្សេងទៀតដូចជា៖

- ដោះស្រាយបញ្ហាដែលកំពុងប្រឈម
- ទាក់ទាញវិនិយោគិនវិស័យឧស្សាហ៍កម្មកាត់ដេរបានច្រើន
- បំពេញបន្ថែមនូវចំណុចដែលខ្វះខាត
- ជួយអភិវឌ្ឍសង្គម ធ្វើឲ្យមានកំនើនសេដ្ឋកិច្ចជាតិ
- ផ្តល់ការគាំទ្រដល់រដ្ឋាភិបាល

## ១.៦. វិធីសាស្រ្តស្រាវជ្រាវ

គម្រោងស្រាវជ្រាវត្រូវពណ៌នា ឬពិសោធ បច្ចេកទេសជ្រើសរើសសំណាកជាការចាំបាច់ ជាពិសេសបើសិនចំនួនសាកលភាពនៃការសិក្សាធំខ្លាំងពេក។ គម្រោងស្រាវជ្រាវជាយុទ្ធសាស្រ្តផែនទីបង្ហាញផ្លូវ។ វាមានសារៈសំខាន់ក្នុងការ ថ្លែងពីកម្មវត្ថុនៃតម្រូវការនិងយុទ្ធសាស្រ្តសម្រាប់ការប្រមូលភស្តុតាងវិភាគភស្តុតាងនិងសរសេររបាយការណ៍របបគំហើយ។

ទិន្នន័យដែលប្រមូលរួចហើយដោយនរណាម្នាក់សម្រាប់បម្រើគោលបំណងស្រាវជ្រាវមួយ បានឆ្លងកាត់តាមរយៈដំណើរការវិភាគតាមឧបករណ៍ស្ថិតិរួចហើយនិងចងក្រងជារបាយការណ៍ ឯកសារ ទាំងផ្សព្វផ្សាយនិងមិនផ្សព្វផ្សាយ។ ប្រភពដែលទទួលបានទិន្នន័យទី២ គឺតាមរយៈការអានសៀវភៅ ការស្រាវជ្រាវលើគេហទំព័រ និងតាមរយៈទិន្នន័យដែលមានស្រាប់របស់រាជរដ្ឋាភិបាល។

## II.យុទ្ធសាស្ត្រទាក់ទាញវិនិយោគិនវិស័យឧស្សាហ៍កម្មកាត់

### ២.១ រំលឹកទ្រឹស្តី

#### ២.១.១ ដូចម្តេចហៅថាការវិនិយោគ?

តាមន័យសេដ្ឋកិច្ចៈ វិនិយោគគឺជាការធ្វើប្រតិបត្តិការដើម្បីបង្កើតមូលធន មានដូចជាទ្រព្យ ក្នុងការរក្សាស្ថេរភាព សម្រាប់បម្រើសេចក្តីត្រូវការ និងចាំបាច់ ។ ការវិនិយោគនេះមានគោលដៅផងដែរដើម្បីបង្កើតតម្លៃនៃបេតិកភណ្ឌ ។ តាមន័យនេះ ការវិនិយោគមានដូចតទៅៈ

- ការបង្កើតជាសហគ្រាស បរទេសដែលមាន បុត្រសម្ព័ន្ធ ការិយាល័យតំណាង និងសាខា ។
- ការទិញសហគ្រាសដែលមានរួចជាស្រេច
- ចូលដើមទុនសម្រាប់សហគ្រាសបង្កើតថ្មី
- ចូលដើមទុនសម្រាប់សហគ្រាសដែលមានស្រាប

តាមន័យគតិយុត្តៈ វិនិយោគជាប្រតិបត្តិការប្រើប្រាស់នូវឧបករណ៍គតិយុត្ត ដើម្បីធ្វើឲ្យសេដ្ឋកិច្ចក្នុងសង្គមដំណើរការបានល្អ។ វាអាចជាការនង្កើតឡើងតាមរយៈប្រើប្រាស់ទុន ឬហ៊ុនដែលជាដើមទុនសម្រាប់បង្កើតគ្រោងសេដ្ឋកិច្ច ដែលបានផ្តល់ឲ្យអ្នកវិនិយោគទុនបានទូលនូវផលចំណេញក្នុងគម្រោងរបស់អ្នកវិនិយោគទាំងនោះ ។

តាមច្បាប់អន្តរជាតិៈ ការវិនិយោគទុនគឺជាការជាប់កិច្ចសន្យារវាងវិនិយោគិនបរទេស និងវិនិយោគិនខ្មែរ លើទឹកដីណាមួយតាមកិច្ចព្រមព្រៀងជាមុនទោះនៅទីណាក៏ដោយដោយអនុលោមតាមច្បាប់ និងបញ្ញាត្តិរបស់ភាគីចុះកិច្ចសន្យា ។

វិនិយោគទុនមានសារៈសំខាន់ដូចតទៅៈ

ការវិនិយោគទុនមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិនៃប្រទេសមួយដែលកំពុងមានការអភិវឌ្ឍន៍ ក៏ដូចជាប្រទេសអភិវឌ្ឍន៍ដែរ ។ ក្នុងវិស័យឯកជនត្រូវបានចាត់ទុកល្មើការវិនិយោគយ៉ាងសំខាន់ជាមួយវិស័យសាធារណៈក្នុងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្នុងគោលបំណងលើកស្ទួយដល់សេដ្ឋកិច្ចជាតិឲ្យបានរីកចំរើនជាបន្តបន្ទាប់ ។ ម្យ៉ាងវិញទៀត សារៈសំខាន់នេះបានជួយ

ផ្តល់ការងារដល់ពលរដ្ឋខ្មែរគ្រប់រូប និងជួយលើកតម្កើនជីវភាពពលរដ្ឋក្រីក្រ ដើម្បីឲ្យមានជីវភាពធុំធ្កើនដូចអប្យប្រទេសក្នុងពិភពលោក នាពេលបច្ចុប្បន្ន ដូច ជាប្រទេស សឹង្ហបូរី ជាដើម ។

### ២.១.២ ដូចម្តេចហៅថាយុទ្ធសាស្រ្តទាក់ទាញ?

ដើម្បីមានការលើកទឹកចិត្តចំពោះអ្នកវិនិយោគដែលបានកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន រដ្ឋាភិបាលត្រូវបង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ក្នុងគោលបំណងមានការធានាសុវត្ថិភាព និងស្ថេរភាពនយោបាយឲ្យបានល្អប្រសើរសម្រាប់ការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាធរជាអ្នកពាក់ព័ន្ធក្នុងការធ្វើកំណែទម្រង់ និងបង្កើតកិច្ចសហប្រតិបត្តិការជាមួយអ្នកវិនិយោគិនដើម្បីលើកទឹកចិត្ត និងផ្តល់ជាមធ្យោបាយផ្សេងៗសម្រាប់ជាតម្រូវការចាំបាច់ក្នុងការប្រកបអាជីវកម្ម ។

#### ក.ការលើកទឹកចិត្ត និងទម្រង់ផ្សេងៗ

ការលើកទឹកចិត្តសំដៅដល់ការផ្តល់នូវផលប្រយោជន៍ផ្សេងៗជាច្រើន ដល់អ្នកវិនិយោគដែលបានអនុវត្តគម្រោងវិនិយោគឲ្យទទួលបាននូវលក្ខណៈសម្បត្តិគ្រប់គ្រាន់(QIP) ។ ការលើកទឹកចិត្តនេះត្រូវមានការលើកលែងផ្នែកពន្ធគយ (១) និង ពន្ធអាករ(២)

#### ១.ការលើកទឹកចិត្តផ្នែកពន្ធគយ

ការលើកទឹកចិត្តលើពន្ធគយនេះ មានការលើកលែងដល់វិនិយោគិន រដ្ឋាភិបាលបានផ្តល់ជូនជាសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង និងធាតុចូលផលិតកម្ម ។ ការលើកលែងនេះត្រូវបានផ្តល់តែលើគម្រោងវិនិយោគណាដែលមានលក្ខណៈសម្បត្តិគ្រាប់គ្រាន់ (QIP) តែប៉ុណ្ណោះ (អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ ឆ្នាំ២០០៥ មាត្រា១៦) ។

QIP បម្រើទីផ្សារក្នុងស្រុក ៖ ជាគោលការណ៍រាជរដ្ឋាភិបាល មានការលើកលែងពន្ធគយនាំចូលទំនិញ ដូចជាសម្ភារៈសំណាង និង សម្ភារៈបរិក្ខាផលិតកម្ម ។ (QIP) មាការបង់ចូលបន្ទាប់ពីមានការត្រួតពិនិត្យត្រីមាសៈ

- ការនាំចេញដោយផ្ទាល់នូវផលិតផលដែលក្រុមហ៊ុនផលិតបាន។
- បានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ ។

QIP បម្រើការនាំចេញ ៖ ទទួលាករលើកលែងពន្ធនាំចូល សម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈ
សំណង់ និង ធាតុចូលផលិតកម្ម ។

QIP ប្រភេទឧស្សាហកម្មគាំទ្រ៖ មានការលើកលែងពន្ធការនាំចូល នូវសម្ភារៈផលិតកម្ម សាងសង់ និងធាតុចូលផលិតកម្ម ។ QIP មិនបានផ្គត់ផ្គង់ ១០០% ចំពោះធាតុចូលផលិតកម្ម នាំចូលមិនបានផ្គត់ផ្គង់ឲ្យឧស្សាហកម្មនាំចេញ បន្ទាប់ពីមានការត្រួតពិនិត្យរបាយការណ៍ត្រីមាស ។

ខ.ការលើកទឹកចិត្តលើពន្ធអាករ

អ្នកវិនិយោគមានសិទ្ធិជ្រើសរើសពន្ធលើប្រាក់រចំណេញ ឬ ការរំលោះពិសេស លើពន្ធអាករ។

ការលើកលែងបពន្ធលើប្រាក់ចំណេញនេះ មានរយៈពេលគន្លឹះ + ៣ ឆ្នាំ + រយៈពេលអាទិភាព ៖

រយៈពេលគន្លឹះ ជាអតិបរមា គឺជាឆ្នាំ ទី១ ទទួលបានប្រាក់ចំណេញ ឬ ៣ ឆ្នាំបន្ទាប់ ទទួលបានប្រាក់ចំណេញឆាប់ជាង ។

រយៈ៣ឆ្នាំ ចាប់គិតពីឆ្នាំសារពើពន្ធបន្ទាប់នៃរយៈពេលគន្លឹះ និង ២ ឆ្នាំបន្តបន្ទាប់ ។

រយៈពេលអទិភាព ជារយៈចាប់គិតភ្លាមបន្ទាប់ពីឆ្នាំសារពើពន្ធទី៣ នៃរយៈពេល ៣ ឆ្នាំ ។

ការរំលោះពិសេស ជាប្រាក់ដែលត្រូវបង់ប្រចាំខែ សម្រាប់ពន្ធលើប្រាក់ចំណេញតាមអាត្រា ០១% នៃផលរបរ គិតរួមបញ្ចូលទាំងអស់ លើកលែងតែអាករលើតុះលៃបន្ថែមបានសម្រេចលើខែមុខ ។

កិច្ចធានា និង កិច្ចការពារដល់អ្នកវិនិយោគ ជាការផ្តល់យុត្តិធំមដល់ពួកគេពេលមានវិវាទ ពុំទាក់ទងនិងប្រាក់កាស។ កិច្ចការពារ និង ការធានាដល់វិនិយោគនេះ ជាកិច្ចការមួយដែលរដ្ឋត្រូវតែយកចិត្តតុកដាក់ លើគម្រោងវិនិយោគរបស់វិនិយោគិន ពិសេសវិនិយោគិនបរទេស ដើម្បីកុំឲ្យប៉ះពាល់ដល់ដំណើរការជោគជ័យវិនិយោគិនទាំងឡាយដែលបានមកដាក់ទុនក្នុងប្រទេសកម្ពុជា ។

ការធានាទាក់ទងប្រាក់កាស ៖

តាមច្បាប់អន្តរជាតិ បានចែងពីការការពារ ប្រាក់កាស របស់អ្នកវិនិយោគិន ។ កិច្ចការពារនេះផ្តោតសំខាន់លើការរំលោភសិទ្ធិ ឬការប៉ះពាល់ដល់ការដកហូតប្រាក់ដោយបំពានលើបទប្បញ្ញត្តិច្បាប់ដែលបានចែង ។ កម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ត្រូវមានការទាមទារតាមច្បាប់អស្សាមិករណ៍ ៖

១. ផ្តល់សំណងរហ័ស , ២. ផ្តល់សំណងសមរម្យពេញលេញ , ៣. ផ្តល់សំណងមានប្រសិទ្ធិភាព យោងតាមសម្រេចសំរេចមហាសន្និបាទអង្គការសហប្រជាជាតិ ១៩៧៤ មាត្រា ២.២ C ។ ដោយមានការផ្តល់សំណងលើសមត្ថភាព

ជា តូបនីយកម្ម (គឺអ្វីជារបស់ឯកជនឲ្យក្លាយទៅជារបស់រដ្ឋ) ។ ដោយការវិនិយោគមានការការពារ និងមានភាពធានា ហេតុនេះរដ្ឋមិនអាចចាត់វិធានការណាមួយដើម្បីដកហូតទ្រព្យសម្បត្តិរបស់វិនិយោគិនតាមវិធីតូបនីយកម្ម ឬប្រវិធានដកហូតសិទ្ធិផ្សេងទៀតចំពោះវិនិយោគបរទេស ដែលមកវិនិយោគនៅលើទឹកដីកម្ពុជាឡើង ។

តាមគោលការណ៍នេះលើកលែងតែអ្នកវិនិយោគិនបរទេសអនុវត្តនូលក្ខខ័ណ្ឌះ

- ដោយស្របច្បាប់ និងបំរើផលប្រយោជន៍សាធារណៈ
- មិនត្រូវធ្វើឡើងដោយមានការរើសអើង
- ត្រូវភ្ជាប់សំណាងយ៉ាងឆាប់រហ័ស ត្រឹមត្រូវ និងមានប្រសិទ្ធិភាព

រីឯច្បាប់ជាតិវិញ គឺច្បាប់ខ្មែរ កិច្ចការពារ និង កិច្ចធានានេះ ដែលទាក់ទងនឹងប្រាក់កាសលើ

គម្រោងវិនិយោគគឺ ៖

**ប្រឆាំងនឹងការរំលោភសិទ្ធិ ៖**

រាជរដ្ឋាភិបាលមិនត្រូវធ្វើតូបនីយកម្ម ដោយសារតែវិនិយោគិនជាសញ្ជាតិបរទេស ដែលមិនបានគរពន្ធវកម្មវត្ថុនៃការរើសអើងឡើយ ។ ការដែលរដ្ឋាភិបាលធ្វើបែបនេះព្រោះតែមិនចង់ឲ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ (ច្បាប់ស្តីពីវិនិយោគ មាត្រា ៩ ឆ្នាំ ១៩៩៤) ។ ចំនែកការដកហូតទ្រព្យសម្បត្តិដោយប្រើច្បាប់អាស្សាមិករណ៍ ច្បាប់ភូកិបាល ដែលមានចែងក្នុងរដ្ឋនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងជៀសវាងកុំឲ្យមានការរំលោភបំពានរវាងបុព្វសិទ្ធិអំណាចសាធារណៈ និង កិច្ចការពារសិទ្ធិឯកជន ។ ការដែលរដ្ឋអនុនត្តច្បាប់អាស្សាមិករណ៍លុះត្រាតែមានលក្ខខណ្ឌដូចមានខាងក្រោមះ

- ធ្វើឡើងដើម្បីផលប្រយោគសាធារណៈ
- ធ្វើឡើងតាមទម្រង់ និង នីតិវិធីច្បាស់លាស់
- ធ្វើបានលុះត្រាណាដែលមានការផ្តល់សំណងជាមុន សមរម្យ និង ពេញលេញ យុត្តិធម៌។

**ការធានាចាត់ចែងទុន និង ទិន្នផល ៖**

តាមគោលការណ៍ជាទូទៅ អ្នកវិនិយោគមានសិទ្ធិសេរីភាពពេញលេញក្នុងការចាត់ចែងទុន និង ទិន្នផលនូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈ

ប្រព័ន្ធធនាគារ លើកលែងតែក្នុងករណីមានអន្តរាគមន៍ពីធនាគារកណ្ដាល ពីបញ្ហាប្ដូរប្រាក់(ច្បាប់ស្ដីពីការគ្រប់គ្រងការប្ដូរប្រាក់ ) ។ មិនតែប៉ុណ្ណោះអ្នកវិនិយោគមានសិទ្ធិសេរីភាពបន្ថែមទៀតក្នុងការប្រើប្រព័ន្ធធនាគារក្នុងការ ៖

- ផ្ទេរប្រាក់ចំណេញ
- បង្វិលទុនវិនិយោគទៅក្រៅប្រទេស បន្ទាប់ពីបានបញ្ចប់ការធ្វើវិនិយោគ
- ការទូទាត់ចំណាយ និងថ្លៃសេវាគ្រប់គ្រង
- ការទូទាត់ក្នុងការនាំចូល
- ការទូទាត់បំណុលតាមរយៈហិរញ្ញប្បទាន

ដូច្នេះដើម្បីឲ្យមានការធានា និង ការពារដល់វិនិយោគបរទេសមកដាក់ទុននៅព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសេរីភាព និងមានតម្លាភាពពិតប្រាកដ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែមានការការពារ និង ធនាលើ សុខសុវត្ថិភាព ឲ្យបានរឹងមាំ ពិសេសពាក់ព័ន្ធលើការធនាយ៉ាងសំខាន់គឺការរើសអើង និង ការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារបានយ៉ាងទូលំទូលាយ ។

### ២.១.៣ ច្បាប់និងគោលនយោបាយទាក់ទាញអ្នកវិនិយោគនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយយ៉ាងសំខាន់ក្នុងការទាក់ទាញអ្នកវិនិយោគទុនពីបរទេស ពិសេសផ្ដោតទៅលើវិស័យឯកជន ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងលទ្ធិប្រជាធិបតេយ្យ ដែលបានចាកឫសយ៉ាងជ្រៅនៅទូទាំងព្រះរាជាណាចក្រកម្ពុជារហូតដល់អនាគតកាល។ កម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍន៍ដែលត្រូវការជាចម្បង គឺការវិនិយោគទុនក្នុងវិស័យឯកជនពីបរទេស ក្នុងគោលបំណងបង្កើននូវថវិការជាតិ ជៀសវាងការសុំជំនួសពីបរទេស ។ ដោយយល់ឃើញថា ការវិនិយោគទុនជាសេដ្ឋកិច្ចដ៏សំខាន់ រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់តម្រូវទៅតាមសេចក្ដីត្រូវការរបស់វិនិយោគិន ទាំងក្នុង និងក្រៅប្រទេស ដើម្បីទាក់ទាញ និងការពារវិនិយោគិននៅកម្ពុជា ឲ្យកាន់តែមានសន្ទុះច្រើនឡើងជាងពេលមុន ។ ការធ្វើកំណែទម្រង់នេះ ស្របតាមច្បាប់ស្ដីពីវិនិយោគឆ្នាំ ១៩៩៤ បានបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC ) ដែលជាស្ថាប័នមួយយ៉ាងសំខាន់បំផុតសម្រាប់អ្នកវិនិយោគងាយស្រួល ទំនាក់ទំនងធ្វើការវិនិយោគនៅកម្ពុជា ហៅថា ច្រកចេញចូលតែមួយ ។ (តាមរយៈច្បាប់វិនិយោគឆ្នាំ១៩៩៤) រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកក្របខ័ណ្ឌគតិយុត្តិ បានផ្ដល់ប្រតិកម្មដូចគ្នា រវាងវិនិយោគិនបរទេស និង ពលរដ្ឋ

ខ្មែរ លើកលែងតែប្រតិកម្មលើកម្មសិទ្ធិដីធ្លី ។ វាជាកិច្ចការពារគតិយុត្ត និង វេធិការពិគ្រោះយោបល់រវាងរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន ។

៣.ចូរនិយាយគ្រួសៗពីការអភិវឌ្ឍន៍នៃក្របខ័ណ្ឌគតិយុត្តជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងការវិនិយោគ?

ក្របខ័ណ្ឌគតិយុត្តជាតិ និង អន្តរជាតិពាក់ព័ន្ធនឹងការវិនិយោគមានដូចតទៅ៖

តាមច្បាប់ជាតិ៖

ច្បាប់ស្តីពីវិនិយោគ ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ ឆ្នាំ ២០០៣ មិនមានការកំណត់និយមន័យបានច្បាស់លាស់ទេ មានប្រើពាក្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺជាគម្រោគវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ។ តាមការកំណត់នៃខ្លឹមសារនៃច្បាប់អាចកំណត់និយមន័យថា ៖ វិនិយោគជាប្រតិបត្តិការមួយដែលធ្វើឡើងដោយប្រើប្រាស់ដើមទុន ដើម្បីអនុវត្តគម្រោងមួយ ឬច្រើន ជាលក្ខណៈសេដ្ឋកិច្ចដែលគម្រោងនេះអាចផ្តល់ឲ្យអ្នកបោះទុនទទួលបាននូវការចំណេញ ឬ ខាត ។

តាមច្បាប់អន្តរជាតិ៖

វិនិយោគសំដៅលើទ្រព្យសម្បត្តិដែលបានដាក់សម្រាប់វិនិយោគ ដោយជនជាតិនៃភាគីជាប់កិច្ចសន្យាមួយលើទឹកដី នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងទទួលស្គាល់ទៅតាមច្បាប់ និងបញ្ញត្តិនានារបស់ភាគីចុះកិច្ចសន្យាដោយរាប់បញ្ចូល ៖

- ចលនទ្រព្យ និង អចលនទ្រព្យ ការដាក់បញ្ចាំដើម្បីធានាប្លាក់ខ្ចី
- សិទ្ធិជាភាគហ៊ុន ប័ណ្ណធានា ឬផលប្រយោជន៍ផ្សេងៗ
- កម្មសិទ្ធិបញ្ញា ក្បួនបច្ចេកទេស ជំនួញ ស្មាដាំយល់ដឹង
- សម្បទានធុរកិច្ច មានតម្លៃសេដ្ឋកិច្ចទទួលស្គាល់ដោយច្បាប់ ឬតាមកិច្ចសន្យាទាក់ទងនឹងវិនិយោគ ។

នៅក្នុងក្របខ័ណ្ឌមាហារណកម្មអាស៊ាន ក្នុងគោលបំណងបង្កើតសហគមន៍សេដ្ឋកិច្ច ពិសេសទាក់ទាញអ្នកវិនិយោគ និងជំរុញអ្នកវិនិយោគប្រកបដោយសន្តិសុខ តម្លាភាព ឲ្យមានលក្ខណៈប្រកួតប្រជែងក្នុងបណ្តាលប្រទេសជាសមាជិកអាស៊ាន ។

ដូច្នោះឃើញឃើញថា ក្នុងក្របខ័ណ្ឌគតិយុត្តជាតិ និង ក្នុងក្របខ័ណ្ឌគតិយុត្តអន្តរជាតិ ត្រូវតែយកមកអនុវត្តក្នុងសមាជិកអាស៊ាន ដើម្បីឲ្យមានតម្លាភាព

និងសន្តិសុខសង្គមបានប្រសើ ព្រមទាំងមានការធានាលើសន្តិសុខ និងស្ថេរភាពនយោបាលសម្រាប់អ្នកវិនិយោគទុនគ្រប់ៗរូប ។

### ២.១.៤ ការវិនិយោគលើវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជា

ខណៈដែលការទាមទារប្រាក់ឈ្នួលខ្ពស់សម្រាប់វិស័យកាត់ដេរកម្ពុជាកំពុងអូសបន្លាយនោះ មានសំណួរថា តើកម្មករកម្ពុជាមានផលិតភាពខ្ពស់ដល់កម្រិតណា? អ្នកជំនាញខាងវិស័យកាត់ដេរ សេដ្ឋកិច្ច និងនយោបាយយល់ឃើញខុសៗគ្នាជុំវិញបញ្ហានេះ។

ប្រាក់ឈ្នួលអប្បបរិមាសម្រាប់កម្មករកាត់ដេរ ដែលទើបតែចូលជាធរមាននាពេលថ្មីៗនេះ មានចំនួន១៨០ដុល្លារក្នុងមួយខែ ក្រោយពីមានបាតុកម្មទាំងអហិង្សា និងហិង្សាអស់រយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ដែលបានបណ្តាលឲ្យកម្មករមួយចំនួនបានបាត់បង់ជីវិត និងជាច្រើននាក់ទៀតរងរបួស។
លោក Ken Loo អគ្គលេខាធិការនៃសមាគមឧស្សាហកម្មកាត់ដេរនៅកម្ពុជា បានអះអាងថា កាលណាប្រាក់ឈ្នួលខ្ពស់ មានន័យថា កម្មករត្រូវតែបង្កើនផលិតភាពឲ្យកាន់តែខ្ពស់ដែរ។ ទាក់ទងនឹងផលិតភាពនេះ លោក Ken Loo យល់ថា ផលិតភាពរបស់កម្មករកម្ពុជាមានកម្រិតទាប។
«ធ្វើការយឺតបើនិយាយពីផលិតភាពវិញ ពួកគេធ្វើការយឺត។! ម្ចាស់រោងចក្រពិបាករកចំណូល បើសិនជាផលិតភាពរបស់កម្មករមិនកើនឡើងនោះ»។
លោកក៏បានបន្ថែមថា បច្ចុប្បន្ននេះការបណ្តាក់ទុនក្នុងប្រទេសកម្ពុជាកំពុងតែថយចុះហើយ។
យ៉ាងណាមិញ យោងតាមព្រឹត្តិប័ត្រព័ត៌មានរបស់អង្គការពលកម្មអន្តរជាតិ (ILO) ឲ្យដឹងថា កម្ពុជាទទួលបានចំណូលចំនួនបីប៊ីលាន ឬបីពាន់លានដុល្លារក្នុងការនាំចេញផលិតផលស្បែកជើង និងសម្លៀកបំពាក់កាត់ដេរក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ២០១៥ ដែលបានកើនលើសឆ្នាំមុនក្នុងអត្រា១២,៧ភាគរយ។
លោក អាត់ ធន់ ប្រធានសហភាពកម្មករកាត់ដេរកម្ពុជា បានសង្កត់ធ្ងន់ថា ផលិតភាពរបស់កម្មករកម្ពុជាអាចប្រកួតប្រជែងនឹងកម្មករនៅប្រទេសផ្សេងៗទៀតដែរ។
«បន្ទាប់ពីនិយោជកចំណាយលើវត្ថុធាតុដើម អន្តរការី និងចំណាយផ្សេងៗហើយកម្មករម្នាក់អាចរកចំណូលដល់និយោជកដល់២៥០ដុល្លារជាង។ ហើយក្នុងនោះកម្មករយើងរកបានតែ១០០ជាងទេ។ ម្នាក់ក្នុងមួយថ្ងៃដេរឲ្យនិយោជកបានជាងហាហុកសិបអាវ បើគិតម្នាក់ៗ»។

ក៏ប៉ុន្តែ លោកថា ភាពខុសគ្នានៃប្រាក់ឈ្នួលអប្បបរិមារវាងប្រទេសកម្ពុជា និងប្រទេសផ្សេងទៀត ដូចជា វៀតណាម និងមីយ៉ាន់ម៉ា ឬភូមា គឺការចំណាយលើថ្លៃរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

«ប្រជាពលរដ្ឋគេការចំណាយរស់នៅប្រចាំថ្ងៃ យើងគិតមើលទៅវាទាបជាងប្រទេសខ្មែរទេ គឺទំនិញគ្រប់ប្រទេសនាំចូលពីវៀតណាមបន្ថែមទៀត។ ចំណែកនៅភូមា យើងដឹងថា ទោះបីជាប្រាក់ឈ្នួលគេមានកម្រិតទាប បើយើងប្រៀបធៀបទៅ វាទាបជាងកម្ពុជាមែន ប៉ុន្តែតម្រូវការការចាយវាយរបស់កម្មកររបស់គេហ្នឹង គឺវាធូរជាងកម្ពុជាយើង តាមអ្វីដែលខ្ញុំបានទៅទីនោះ»។

លោក អាត់ ធន់ បានបន្ថែមថា ការកំណត់ប្រាក់ឈ្នួលអប្បបរិមាត្រូវតែស្របទៅតាមការចំណាយលើថ្លៃរស់នៅប្រចាំថ្ងៃ។

«ការផ្ដល់ប្រាក់បៀវត្សរ៍អប្បបរិមាគឺគេអាស្រ័យទៅលើស្ថានភាពជីវភាពនៃប្រជាពលរដ្ឋរបស់ប្រទេសនោះ។ គេមិនអាស្រ័យទៅលើចំនួនច្រើន ចំនួនតិចនោះទេ»។

នៅពេលដែលប្រទេសមីយ៉ាន់ម៉ា ឬភូមាបានកំណត់ប្រាក់ឈ្នួលអប្បបរិមាដល់កម្មករប្រមាណ៦៧ដុល្លារក្នុងមួយខែ លោក Thomas Rhoden អ្នកជំនាញខាងនយោបាយនៅមីយ៉ាន់ម៉ា ឬភូមា បានឲ្យដឹងថា អ្នកវិនិយោគទុនមើលឃើញប្រទេសនេះថា ជាប្រទេសដែលមានភាពប្រកួតប្រជែងល្អក្នុងវិស័យកាត់ដេរ។

«ឧស្សាហកម្មកាត់ដេរនៅប្រទេសមីយ៉ាន់ម៉ាទទួលបានការវិនិយោគទុនដ៏ធំ»។

ក៏ប៉ុន្តែ លោកមិនច្បាស់ថា តើលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងមេដឹកនាំប្រទេសមីយ៉ាន់ម៉ាកាលពីថ្ងៃអាទិត្យនេះនឹងប៉ះពាល់ដល់ឧស្សាហកម្មកាត់ដេររបស់ប្រទេសនេះដល់កម្រិតណានោះទេ។

ទាក់ទងនឹងបញ្ហាដ៏ប្រទាក់ក្រឡាគ្នានេះ លោក ហេង ឌីណា សេដ្ឋវិទូខ្មែរមួយរូបប្រចាំនៅរដ្ឋធានីវ៉ាស៊ីនតោន បានណែនាំថា កាលណាកម្ពុជាអាចពង្រឹងគុណភាពផលិតផលកសិកម្មបែបឧស្សាហកម្មឲ្យបានល្អនោះ នោះតម្លៃម្ហូបអាហារនឹងថយចុះ ដែលអាចធ្វើឲ្យការចំណាយលើថ្លៃរស់នៅថយចុះ។ ការណ៍នេះនឹងផ្ដល់ផលចំណេញច្រើនដល់កម្មករ។

«បើសិនបើយើងអាចផលិតម្ហូបអាហារ បន្លែ សាច់ ម្ហូបអាហារថោកជាងមុន វាអាចជួយដល់ផលិតភាពដែរ ដោយសារប្រជាជនយើងអាចបរិភោគអាហារថោកជាងមុន។ អញ្ចឹងការចាយវាយ វាអាចថោកជាងមុន។ មានន័យថា គាត់ពុំចាំបាច់ទាមទារប្រាក់ខែខ្ពស់ជាងមុនទេ ដើម្បីឲ្យគាត់ខំប្រឹងជាងមុន»។

លោកបានបន្ថែមទៀតថា អ្នកដែលមានតួនាទីសំខាន់ក្នុងការពង្រឹងផលិតភាព

ខ្ពស់របស់កម្មករគឺរដ្ឋាភិបាល ដែលត្រូវធ្វើឲ្យសេវាថែទាំសុខភាពមានតម្លៃសមរម្យ និងគុណភាពល្អ ហើយនិងពង្រឹងគុណភាពអប់រំ។
បញ្ហាដែលយើងត្រូវមើលសំខាន់តទៀតនោះគឺខាងវិស័យអប់រំ និងសុខាភិបាលដែលអាចជួយពង្រឹងផលិតភាពរបស់កម្មករយើង។ ជាឧទាហរណ៍ បើសិនជាគាត់អាចមានសុខភាពល្អជាងមុន គាត់អាចមានចំណេះដឹងជាមូលដ្ឋានល្អជាងមុន ដែលអាចចាប់យកជំនាញថ្មីៗ។ វាអាចជួយមួយកម្រិត។
កម្ពុជាទទួលបានចំណាត់ថ្នាក់ទី៨ក្នុងចំណោមប្រទេសចំនួន១៥ដែលនាំមុខគេក្នុងការនាំចេញផលិតផលស្បែកជើង និងសម្លៀកបំពាក់កាត់ដេរក្នុងឆ្នាំ២០១៤ដែលកម្ពុជាបាននាំមុខប្រទេសថៃ និងម៉ាឡេស៊ីក្នុងតំបន់។ យ៉ាងណាមិញអនាគតនៃវិស័យនេះមិនទាន់មានភាពប្រាកដប្រជានៅឡើយទេ៕

## ២.២ កត្តាចជាយុទ្ធសាស្ត្រទាក់ទាញអ្នកវិនិយោគក្នុងវិស័យកាត់ដេរនៅកម្ពុជា

### ២.២.១ សន្តិសុខសុវត្ថិភាព

គឺនៅពេលដែលមនុស្សអាចដោះស្រាយការប៉ះទង្គិចដោយគ្មានការប្រើអំពើហិង្សា ហើយអាចធ្វើការជាមួយគ្នាដើម្បីធ្វើអោយប្រសើរឡើងគុណភាពជីវិតរបស់ពួកគេ។ សុខសុវត្ថិភាពគឺនៅពេលដែល៖

មនុស្សគ្រប់រូបរស់នៅក្នុងសុវត្ថិភាពដោយគ្មានការភ័យខ្លាចឬការគំរាមកំហែងនៃអំពើហិង្សានិងគ្មានទម្រង់អំពើហិង្សាត្រូវបានអត់ឱននៅក្នុងច្បាប់ឡើយ។
មនុស្សគ្រប់គ្នាគឺមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ប្រព័ន្ធតុលាការគឺអាចជឿទុកចិត្តបាននិងភាពយុត្តិធម៌និងប្រសិទ្ធិភាពនៃច្បាប់ក្នុងការការពារសិទ្ធិរបស់ប្រជាជន។

មនុស្សគ្រប់រូបគឺអាចចូលរួមនៅក្នុងការសម្រេចចិត្តនយោបាយនិងរាជរដ្ឋាភិបាលមានគណនេយ្យភាពចំពោះប្រជាជន។
មនុស្សគ្រប់រូបមានសិទ្ធិចូលដំណើរការដោយស្មើភាពទៅនឹងតម្រូវការមូលដ្ឋានសម្រាប់សុខុមាលភាពរបស់ពួកគេ ដូចជាអាហារ ទឹកស្អាត ជម្រក ការអប់រំការថែទាំសុខភាពនិងបរិស្ថានរស់នៅសមរម្យ។

មនុស្សគ្រប់រូបមានឱកាសស្មើគ្នាក្នុងការធ្វើការនិងធ្វើឱ្យការរស់នៅមួយដោយមិនគិតពីភេទ ជាតិសាសន៍ឬទិដ្ឋភាពផ្សេងទៀតណាមួយនៃអត្តសញ្ញាណឡើយ។

សន្តិសុខសុវត្ថិភាព កត្តាសុខសន្តិភាព និងស្ថិរភាពនយោបាយ គឺជាចំណុចសំខាន់ដើម្បីធានាការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចមានចីរភាពសម្រាប់ប្រទេសកម្ពុជានិងតំបន់ទាំងមូល។ ជាពិសេសនោះ គឺជាកត្តាយុទ្ធសាស្ត្រក្នុងការទាក់ទាញវិនិយោគិនបរទេសចូលមកកម្ពុជា ។

ចីរភាពនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចអាចធ្វើទៅបាន លុះត្រាតែប្រទេសជាតិធានាឲ្យបាននូវសុខសន្តិភាព និងស្ថិរភាពនយោបាយពេញលេញជាមុនសិន ដែលចាត់ទុកថាជាកត្តាសំខាន់បំផុតមិនអាចខ្វះបាន។ កត្តាយុទ្ធសាស្ត្រឈានទៅដល់ការបង្រួបបង្រួមជាតិបានធ្វើអោយកម្ពុជាចាប់ផ្តើមដំណើរការសេដ្ឋកិច្ចទីផ្សារមួយដែលសមស្របសម្រាប់ប្រទេសជាតិ។កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់កម្ពុជាផងដែរ។ដែលក្នុងនោះពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៣ កំណើនសេដ្ឋកិច្ចបានកើនឡើងជិត ៩% និងការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសក្នុងវិស័យទេសចរណ៍ និងឧស្សាហកម្មកាត់ដេរ។

វិស័យកាត់ដេរ និងទេសចរណ៍ដែលត្រូវលោក ហ៊ុន សែន ឲ្យដឹងថា បានក្លាយជាគន្លឹះសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ទន្ទឹមនឹងជំនួយអភិវឌ្ឍន៍ផ្លូវការនានា។ នៅចំពោះមុខអ្នកចូលរួម មកពីស្ថាប័នជាតិ និងអន្តរជាតិ នៅចន្លោះឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៨ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យម ១០,៣៧% ទិដ្ឋភាពនេះជាលើកទី១ ដែលកម្ពុជាអាចសម្រេចកំណើនពីរខ្ទង់ជាប់ៗគ្នា ហើយសន្ទុះដ៏ល្អប្រសើរនេះក៏ដោយសារតែមានការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ លំហូរវិនិយោគផ្ទាល់ពីបរទេស និងជំនួយអភិវឌ្ឍន៍ផ្លូវការផងដែរ។

រដ្ឋាភិបាលកម្ពុជាក៏បានលើកឡើងពីកំណើននៃផលិតផលក្នុងស្រុក ចំណូលជាមធ្យមរបស់ប្រជាជនកម្ពុជាម្នាក់បានកើនឡើង៣ដង គឺពី២២៩ ដុល្លារ ឡើងដល់ ៧៣៩ ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ អត្រានៃភាពក្រីក្រក៏បានធ្លាក់ចុះពី

ប្រមាណ ៥០ មកត្រឹម ១៩៩៣ ក្នុងឆ្នាំ %៣០ បន្តការធ្លាក់ចុះជាបន្តបន្ទាប់ % ២៧ គឺ ២០០៧ ទៀតក្នុងឆ្នាំ,៩និន្នាការនៃការធ្លាក់ចុះ ២០០៩ ។ នៅក្នុងឆ្នាំ% អត្រានៃភាពក្រីក្រនេះត្រូវរដ្ឋាភិបាលកម្ពុជារំពឹងថានឹងបន្តកើតមានទៀត។ ជាមួយគ្នានេះដែរ រដ្ឋាភិបាលកម្ពុជា ក៏បានលើកឡើងពីការធ្វើសមាហរណកម្មផ្ទៃក្នុង ដែលមានន័យស្មើនឹងការធ្វើសមាហរណកម្មជាមួយប្រទេសដទៃទៀតនៅក្នុង តំបន់ ដើម្បីប្រយុទ្ធប្រឆាំងនឹង វិបត្តិសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍន៍នៅក្នុងតំបន់។

### ២.២.២ ធនធានមនុស្ស

គឺជាមនុស្សដែលបង្កើតជាកម្លាំងពលកម្មនៃ

អង្គភាពមួយ វិស័យ

អាជីវកម្មឬសេដ្ឋកិច្ច។មូលធនមនុស្សគឺពេលខ្លះត្រូវបានប្រើដូចនិងន័យធនធានមនុស្សដែរ។ ធនធានមនុស្ស បញ្ហាសំខាន់មួយទៀតដែលគេមិនអាចមើលរំលងបាននោះ គឺកង្វះការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ពលករ

ខ្មែរ។ ជាទូទៅពួកគេមានតែកម្លាំងពលកម្មសុទ្ធសាធសម្រាប់បម្រើការងារ តែគ្មានចំណេះ ជំនាញអ្វីក្នុងខ្លួនឡើយ។ សូម្បីតែក្នុងវិស័យសំណង់ កម្ពុជាក៏នៅតែបន្តត្រូវការកម្មករជំនាញជនជាតិវៀតណាមដែរ។ នេះសបញ្ជាក់ឲ្យឃើញថា ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ គឺជាសេចក្តីត្រូវការចាំបាច់សម្រាប់ពលករខ្មែរ។ ការបណ្តុះបណ្តាលធនធានមនុស្សជារឿងសំខាន់សម្រាប់ជំរុញឲ្យសេដ្ឋកិច្ចលូតលាស់ទៅមុខ ជាទូយ៉ាងរដ្ឋាភិបាលគួរកែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ ( Soft Skills) រួមមាន ជំនាញទំនាក់ទំនងសសង្គមក្នុងការដោះស្រាយបញ្ហា ការគោរពវិន័យនៅកន្លែងធ្វើការ និងជំនាញជាច្រើនទៀត ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្ម។លើសពីនេះទៅទៀតការពង្រឹងការយល់ដឹងអប់រំអំពីការចាប់អាជីពជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្តដើម្បីអភិវឌ្ឍជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមនាស្រាប់។ ហើយបង្កើនការបណ្តុះបណ្តាលបច្ចេកទេសឲ្យបាន

ច្រើនជាងមុន តាមលទ្ធភាពលើជំនាញបច្ចេកទេស ជាពិសេសនៅក្នុងផ្នែកអគ្គិសនី អេឡិចត្រូនិច មេកានិច ស្តង់ដា មាត្រាសាស្ត្រ និងគីមីសាស្ត្រទាំងក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេសនិងឧត្តមសិក្សា។

ម្យ៉ាងទៀតត្រូវផ្តល់អាទិភាពដល់ការបង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឲ្យបានច្រើន ដោយផ្តោតលើផ្នែកសំខាន់ៗ ដូចជា ការកែច្នៃកសិផលនិងសិប្បកម្ម រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេសនិងវិទ្យាសាស្ត្រ ដែលបម្រើឲ្យវិស័យឧស្សាហកម្ម។ (គោលនយោបាយរាជរដ្ឋាភិបាល ឆ្នាំ២០១៥-២០២៥)

២.២.៣ គោលនយោបាលពន្ធ គឺជាជម្រើសមួយដោយរដ្ឋាភិបាលថាជាអ្វីពន្ធដើម្បីជកហូតនៅអ្វីដែលមានចំនួននិងនៅលើដែល។វាមានទាំងទិដ្ឋភាពមីដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ច។ ទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចទាក់ទងបរិមាណសរុបនៃពន្ធក្នុងការប្រមូលដែលផ្តុយគ្នាកម្រិតដែលអាចប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចនេះគឺជាសមាសភាគមួយនៃគោលនយោបាយសារពើពន្ធ។ គោលនយោបាលពន្ធ វិស័យកាត់ដេរសម្រាប់នាំចេញ ស្ថិតក្នុងចំណោមវិស័យវិនិយោគ ដែលទទួលបាននូវការអនុគ្រោះពន្ធ។ នៅក្នុងរយៈពេលអនុគ្រោះពន្ធនេះ (ដែលក្នុងករណីខ្លះអាចមានរយៈពេលរហូតដល់ទៅ ៩ឆ្នាំ) រោងចក្រកាត់ដេរត្រូវរួចពន្ធ ទាំងទៅលើប្រាក់ចំណេញ និងទាំងពន្ធគយទៅលើការនាំចូលសម្ភារៈ ដែលចាំបាច់ក្នុងការផលិត ដូចជា វត្ថុធាតុដើម និងគ្រឿងម៉ាស៊ីនផ្សេងៗ ជាដើម។

### ២.២.៤ អភិបាលកិច្ចល្អ

គឺជាពាក្យបច្ចេកទេសមួយក្នុងការអភិវឌ្ឍន៍ជាអន្តរជាតិដើម្បីរៀបអង្គការរដ្ឋក្នុងការប្រតិបត្តិការងារសាធារណនិងការគ្រប់គ្រងធនធានសាធារណៈ។ អភិបាលកិច្ច គឺជានិតិវិធីនៃសំរេចចិត្តនិងវិធីដែលការសំរេចចិត្តត្រូវបានអនុវត្ត រឺក៏មិនត្រូវបានអនុវត្ត " ពាក្យ អភិបាលកិច្ច អាចប្រើប្រាស់ដើម្បី សហការលើផ្នែកអន្តរជាតិ ក្នុងប្រទេស និងតាមតំបន់ក្នុងការអនុវត្តអភិបាលកិច្ច រឺក៏ដើម្បីការទំនាក់ទំនងរវាងផ្នែកផ្សេងៗនៅក្នុងសង្គម។ អភិបាលកិច្ចល្អ ការិយាល័យ

ធិបតេយ្យ បានជះឥទ្ធិពលថ្លៃដើមនៃផលិតកម្មកាត់ដេរ ដោយផ្អែកលើរបាយការណ៍របស់ធនាគារពិភពលោក ស្ដីពីខ្សែរសង្វាក់តម្លៃថា ចំណាយខ្ពស់លើ

ប្រតិវេទគយ និងបែបបទផ្សេងៗ ធ្វើអោយមានការលំបាក់ដល់ការប្រកួតប្រជែងរបស់កម្ពុជា។ ព្រឹត្តិប័ត្រនេះ បានគូសបញ្ជាក់ថា អ្នកគ្រប់គ្រងនៅក្នុងឧស្សាហកម្មកាត់ដេរបានចំណាយពេលយ៉ាងច្រើនរបស់ខ្លួន (១៦%) ក្នុងការជួយដោះស្រាយជាមួយមន្ត្រីរដ្ឋាភិបាល ហើយមានភាពស្មុគស្មាញនៃ បែបបទនាំចេញនិងចំណាយក្រៅផ្លូវការ មានតម្លៃស្មើរនឹង ៧% នៃថ្លៃលក់សរុប។ (MPDF, 2004) លើសពីនេះទៅទៀត ការបន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគនិងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខណ្ឌគតិយុត្តការធ្វើវិចារណកម្មការផ្តល់ការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគ ការបន្តពង្រឹងក្របខណ្ឌអភិបាលកិច្ច និងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ ពិសេស ការពង្រឹងយន្តការ « ច្រកចេញចូលតែមួយនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឲ្យក្លាយជាយន្តការជាក់ស្តែងប្រកបដោយប្រសិទ្ធភាព សម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម។ ហើយអ្វីដែលគួរពិចារណាទៀតនោះគឺ ពង្រឹងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការវិនិយោគ និងដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិន ក្នុងដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ។ គួរគប្បីបន្តពង្រឹងប្រសិទ្ធភាពនៃ វេទិការាជរដ្ឋាភិបាលនឹង

វិស័យឯកជនដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេសការធានានូវផលប្រយោជន៍រួមនៃវិស័យឧស្សាហកម្មការប្រកួតប្រជែងស្មើភាពនិងការលើកកម្ពស់បរិយាកាសវិនិយោគ។

(គោលនយោបាយរាជរដ្ឋាភិបាលឆ្នាំ(២០១៥-២០២៥)

### ២.២.៥ ហេដ្ឋារចនាសម្ព័ន្ធ

គឺសំដៅទៅលើរចនាសម្ព័ន្ធប្រព័ន្ធនិងបរិក្ខារបម្រើសេដ្ឋកិច្ចរបស់ប្រទេសមួយ ទីក្រុង ឬតំបន់ រួមទាំងការផ្តល់សេវានិងបរិក្ខារចាំបាច់សម្រាប់សេដ្ឋកិច្ចរបស់ខ្លួនដើម្បីដំណើរការបាន។ ជាធម្មតាវាជាលក្ខណៈរចនាសម្ព័ន្ធបច្ចេកទេស

ដូចជាផ្លូវថ្នល់ស្ពានផ្លូវរូងក្នុងដីផ្គត់ផ្គង់ទឹកលូបណ្តាញអគ្គិសនីទូរគមនាគមន៍ជាដើមនិងអាចត្រូវបានកំណត់ជាសមាសភាគប្រព័ន្ធប្រទាក់ក្រលារាងកាយនៃទំនិញនិងសេវាកម្មការផ្តល់សារៈសំខាន់ដើម្បីដំណើរការ មាននិរន្តភាព ឬការលើកកម្ពស់ជីវភាពរស់នៅក្នុងសង្គម។ ពាក្យហេដ្ឋារចនាសម្ព័ន្ធត្រូវបានគេប្រើនៅក្នុងភាសាអង់គ្លេសចាប់តាំងពីឆ្នាំ១៨៨៧ហើយនៅក្នុងប្រទេសបារាំងចាប់តាំងពីឆ្នាំ១៨៧៥ដែលមានដើមកំនើតន័យថាការដំឡើងដែលបង្កើតមូលដ្ឋានសម្រាប់ការប្រតិបត្តិ។ ទោះបីមានការខិតខំប្រឹងប្រែងជាខ្លាំងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងរយៈពេល២០ឆ្នាំកន្លងមកហេដ្ឋារចនាសម្ព័ន្ធទាំងនោះនៅតែមិនគ្រប់គ្រាន់ ពិសេស ក្នុងដំណើរការឆ្ពោះទៅដំណាក់កាលថ្មីនៃការអភិវឌ្ឍ។ ការជំរុញការនាំចេញអង្ករមួយលានតោន បានឆ្លុះបញ្ចាំងឲ្យឃើញនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ថែម ដើម្បីធានាឲ្យបាននូវខ្សែចង្វាក់ផ្គត់ផ្គង់ដែលអាចទុកចិត្តបានទាន់ពេលវេលា។បណ្តាញផ្លូវជាតិសំខាន់ៗ សម្រាប់ជំរុញការនាំចេញទទួលរងនូវភាពកកស្ទះដែលនាំទៅដល់ការពន្យាពេលដឹកជញ្ជូននិងដាក់បន្ទុកកាន់តែខ្លាំងលើផ្លូវក្នុងទំហំបច្ចុប្បន្ន។ដូច្នេះការជំរុញការអភិវឌ្ឍឧស្សាហកម្មនិងការនាំចេញបន្ថែម បង្កើតឡើងនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀតពិសេសនៅតាមតំបន់ដែលជាទិសដៅនៃការអភិវឌ្ឍឧស្សាហកម្មនិងការដឹកជញ្ជូនតាមមាត់ច្រកនាំចេញដែលគូសបញ្ជាក់អំពីភាពចាំបាច់នៃការអភិវឌ្ឍប្រព័ន្ធឡូជីស្ទីកមួយឲ្យមានប្រសិទ្ធភាព។ (គោលនយោបាយរាជរដ្ឋាភិបាលឆ្នាំ២០១៥-២០២៥)។

ជាសរុបការសិក្សាកត្តាយុទ្ធសាស្ត្រក្នុងការទាក់ទាញវិនិយោគិនវិស័យឧស្សាហកម្មកាត់ដេរមកកម្ពុជាពិតជាមានភាពជាប់ទាក់ទងជាមួយកត្តាដូចជា៖ សន្តិសុខសុវត្ថិភាព ធនធានមនុស្ស គោលនយោបាលពន្ធ អភិបាលកិច្ចល្អ និងហេដ្ឋារចនាសម្ព័ន្ធ។

### ៣.សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ៣.១ សន្និដ្ឋាន

ដោយសារតែកាលពីមុនឆ្នាំ១៩៩៣ មិនទាន់មានការចុះនៃកិច្ចព្រមព្រៀងទីក្រុងបារីស សេដ្ឋកិច្ចប្រទេសកម្ពុជាជាសេដ្ឋកិច្ចបែបផែនការ ។ បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១មក សេដ្ឋកម្ពុជាបែបជាសេដ្ឋកិច្ចទីផ្សារសេរី ។ មានការអនុគ្រោះពន្ធពី WTO និង ឈានចូលជាសមាជិកអាស៊ានផងដែរ។ ស្ថានភាពនៃការវិនិយោគនាពេលបច្ចុប្បន្ន រដ្ឋអាចធ្វើការចាប់ដៃជាមួយវិស័យឯកជន លើគ្រប់វិស័យក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ។

ការវិនិយោគបានបង្កើនការងារដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប មានការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបង្កើនថវិការជាតិលើការប្រមូលពន្ធ ។ អាចធ្វើឲ្យកម្ពុជាមានឈ្មោះបោះសំលេងលើឆាកអន្តរជាតិ ព្រមទាំងមានកិត្តិយសផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជាបានយល់ច្បាស់ក្នុងការសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច ជាតិដោយមិនពឹងលើការជំនួយ និងការខ្ចីបរទេសឡើយ ។ ដែលមានវិស័យឯកជនវិនិយោគជួយក្នុងវិស័យសេដ្ឋកិច្ចរួចជាស្រេច។

រាជរដ្ឋាភិបាលកំពុងអនុវត្តកំណែទម្រង់ជាច្រើនដើម្បីបង្កឲ្យវិនិយោគមានជំនឿទុកចិត្តលើរាជរដ្ឋាភិបាលកម្ពុជាពិតប្រាកដ ។ រដ្ឋត្រូវលើកទឹកចិត្តដល់អ្នកវិនិយោគិន និងការពារវិនិយោគិនឲ្យទទួលបានណុវត្ថិភាពពិត ។ រដ្ឋាភិបាលបានបង្កើត CDC ដែលចេញពីច្បាប់វិនិយោគឆ្នាំ ១៩៩៤ គឺជាការទំនាក់ទំនងបានយ៉ាងងាយស្រួល ច្រកចេញចូលតែមួយដើម្បីងាយស្រួលដល់វិនិយោគិនទំនាក់ទំនងក្នុងការបង្កើតអាជីវកម្មដែលមានទ្រង់ទ្រាយធំ ។

ពិសេសរាជរដ្ឋាភិបាលខិតខំទាក់ទាញអ្នកវិនិយោគបរទេស តាមរយៈការពង្រឹងក្របខណ្ឌគតិយុត្តរវាងអ្នកវិនិយោគិនខ្មែរដូចគ្នានឹងវិនិយោគិនបរទេសដែរដែលមកវិនិយោគនៅកម្ពុជា។ លើកលែងតែកម្មសិទ្ធិលើដីធ្លីនិងការអនុវត្តជាក់ស្តែងនៃប្រតិបត្តិការវិនិយោគនៅកម្ពុជា ។

សរុបសេចក្តីមកការវិនិយោគនៅកម្ពុជានាពេលបច្ចុប្បន្ន ពិតជាមានផលប្រយោជន៍យ៉ាងពិតប្រាកដ ក្នុងការទាញយកអ្នកវិនិយោគិនបរទេសក៏ដូចជាវិនិយោគខ្មែរ ដែលទាំងអស់នោះអាចបង្កើនថវិការជាតិបានយ៉ាងច្រើនសន្ធឹកសន្ធាប់សំរាប់អភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយមោទនភាពលើឆាកអន្តរជាតិ។

## ៣.២ អនុសាសន៍

កិច្ចការស្រាវជ្រាវនេះគឺត្រូវបានប្រើជាគំរូសម្រាប់អ្នកស្រាវជ្រាវផ្សេងទៀតដើម្បីធ្វើការស្រាវជ្រាវបន្តជាពិសេសសិស្សដែលចង់ធ្វើការអភិវឌ្ឍចំនេះដឹងអោ

សាកលវិទ្យាល័យជាតិគ្រប់គ្រង

យមានភាពប្រសើរឡើងនិងជួយដល់រាជរដ្ឋាភិបាលសិក្សាបន្ថែមនូវចំនុចខ្វះខាត។សម្រាប់កិច្ចការស្រាវជ្រាវទៅមុខទៀតយើងគួរចាំបាច់ផ្តោតអារម្មណ៍លើមូលហេតុអ្វីដែលរោងចក្រភាគច្រើនបានទ្វាហើយបានចេញទៅវិនិយោគនៅឯប្រទេសជិតខាងទៅវិញនិងលក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រ។ ដើម្បីឲ្យស្ថានភាពវិនិយោគនៅកម្ពុជាកាន់តែមានភាពល្អប្រសើរឡើងថែមទៀតរាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់លើកត្តាជាច្រើនដូចខាងក្រោម៖

- ផ្តល់នូវសុវត្ថិភាពជូនអ្នកវិនិយោគ
- ធ្វើការកំណែទម្រង់ និងបង្កើតកិច្ចសហប្រតិបត្តិការជាមួយវិនិយោគ
- ផ្តល់ការលើកទឹកចិត្ត
- លើទឹកចិត្តផ្នែកពន្ធគយ
- បម្រើទីផ្សារក្នុងស្រុក
- មានលទ្ធភាពនាំចេញដោយផ្ទាល់នូវផ្នែកណាមួយនៃផលិតផលខ្លួនផលិតបាន
- បានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ
- ការលើកទឹកចិត្តលើផ្នែកចំណេញ
- ការអនុគ្រោះពន្ធលើប្រាក់ចំណេញ
- ការរំលោះពិសេស ។

សាកលវិទ្យាល័យជាតិគ្រប់គ្រង

## ឯកសារយោង


I. Sophal, E. (2009) Sowing and Sewing Growth: The Political Economy of Rice and Garments in Cambodia, No.384.

II. Alam, M.S. (2012) The Competitive Factors of the Garment Industry During the Post Multi-Fibre Arrangement (MFA) Period: Empirical Evidence from Bangladesh.

III. Chansamphors, C. (2008) The Standard of Living of Garment Workers in Cambodia: Its Determinants and Workers' Perception, No.26.

IV. Anthony, A. R. (2003) International Development Association and International Monetary Fund.

V. CCHR, (2004) "Workers' Rights are Human Rights" Policy Brief: The Garment Industry in Cambodia.

VI. Nick J, F. (2002) Foreign Direct Investment in Cambodia, Lao and Vietnam: A Regional Overview.

VII. Sukti, D. (2011) from downturn to recovery: Cambodia's garment sector in transition.

VIII. Saha Dhevan, M. (1994) Managing Restructuring in the Textile and Garment Subsector Examples from Asia.

IX. Link: https://thmeythmey.com/?page=detail&id=33156

X. Link: https://thmeythmey.com/?page=detail&id=33156


សាកលវិទ្យាល័យជាតិគ្រប់គ្រង

NUML-Book Barcode
B-009521
សាកលវិទ្យាល័យជាតិគ្រប់គ្រង